LIBRARY
BUDDHIST INSTITUTE

# កុម្ភជាតក

ពុទ្ធិកសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ព. ស. ២៥០១

ថ្លៃ ៣រ.០០

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh** **www.elibraryofcambodia.org**

# កុម្ភជាតក

សំដែងអំពីដើមកំណើតសុរានិងទោសនៃសុរា

លោកអាចារ្យ ឈឹម ស៊ុម សទ្ធម្មប្បញ្ញោ

គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

ប្រែនិងរៀបរៀងតាមគម្ពីរខុទ្ទកនិកាយ ព្រមទាំងអដ្ឋកថា

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ បានអនុញ្ញាតហើយ

បោះពុម្ពលើកទី ២

INSTITUT BOUDDHIQUE

LIBRARY
BUDDHIST INSTITUTE

១៦៨/៩៥

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥០១

# KUMBHAJĀTAKA

TRADUIT DU PĀLI EN CAMBODGIEN

PAR

LE VÉNÉRABLE CHHIM-SOUM

PROFESSEUR A L'ÉCOLE SUPÉRIEURE DE PĀLI

Cette Publication a reçu l'approbation du Conseil des Ministres

et des deux Chefs de Secte

Deuxième Édition

PHNOM-PENH

ÉDITIONS DE L'INSTITUT BOUDDHIQUE

1958

# អារម្ភកថា

កុម្ភជាតកនេះ ជាជាតក ១ ដែលមានប្រាកដក្នុងព្រះត្រៃបិដក គម្ពីរខុទ្ទកនិកាយជាតក តឹសនិបាត ជាភាសាបាលី ខ្ញុំបានប្រែនិងរៀបរៀងសេចក្ដីជាខេមរភាសា ដោយសេចក្ដីត្រូវការរបស់លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។

ក្នុងវេលាដែលខ្ញុំប្រែនិងរៀបរៀងនោះ ខ្ញុំបានពិនិត្យយកសេចក្ដីពីគម្ពីរអដ្ឋកថានៃគម្ពីរនេះមកដាក់បញ្ចូលផង ដើម្បីឲ្យទាក់ទងសេចក្ដីគ្នា ជាលំអានល្អស្ដាប់បានដោយងាយ ៗ ឯសេចក្ដីដែលពោលតាមគម្ពីរខុទ្ទកនិកាយជាតក តឹសនិបាតនោះ ខ្ញុំដាក់ទាំងបាលី ព្រមទាំងសេចក្ដីប្រែជាសម្រាយផង ឥតមានរំលងត្រង់គាថាណាមួយឡើយ រួមទាំងអស់ ៣១ គាថា តែសេចក្ដីប្រែនោះ មិនមែននិយមព្យញ្ជនៈជាប្រមាណទេ ប្រែនិយមយកអត្ថរសជាប្រមាណ តាមទំនងសេចក្ដីនៃគម្ពីរអដ្ឋកថា ។

ខ្ញុំខំធ្លៀតធ្វើរឿងនេះ ក្នុងពេលឱកាសមួយស្របគ្នា ដែលក្រៅអំពីពេលធ្វើការជាប្រក្រតី ដរាបតែចប់សព្វគ្រប់ ហើយបានយកទៅប្រគេនព្រះតេជ-គុណព្រះសិរីសម្មតិវង្ស ព្រះនាម " ឯម " ចាងហ្វាងសាលាបាលីជាន់ខ្ពស់ និងជាអធិបតីក្រុមជំនុំព្រះត្រៃបិដក ដែលជាឧបជ្ឈាចារ្យរបស់ខ្ញុំ និងព្រះតេជ-គុណព្រះឧត្ដមមុនី ព្រះនាម " ស៊ូ " អធិបតីរងក្រុមជំនុំព្រះត្រៃបិដក សូមឲ្យលោកពិនិត្យឲ្យ ។ លោកក៏បានពិនិត្យ

ឲ្យផ្សាយសេចក្ដីមេត្តា ហើយខ្ញុំយករឿងនេះទៅជូនលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ឲ្យលោកចាត់ការបោះពុម្ព ដើម្បីផ្សាយដល់ពួកពុទ្ធសាសនិកជន គ្រប់ជម្សូនដែលមានសេចក្ដីត្រូវការ ។

ខ្ញុំសូមប្រគេនបុញ្ញរាសី ដែលកើតអំពីវិរិយភាពរបស់ខ្ញុំនេះទាំងអស់ ចំពោះព្រះតេជ-គុណទាំងពីរព្រះអង្គនោះ ដើម្បីជាបតិការៈគុណព្រះគុណដ៏ធំទូលាយ សូមឲ្យព្រះគុណបានសម្រេចនូវឥដ្ឋមនុញ្ញផលតាមគាប់ព្រះទ័យ ហើយសូមសេចក្ដីសុខ-ចំរើនមានដល់ខ្ញុំផង ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់អស់លោក-អ្នកដែលប្រព្រឹត្តតាមព្រះពុទ្ធសាសនាផង អស់កាលជាអង្វែងទៅហោង ។

លោកអាចារ្យ ឈឹម-ស៊ុម សទ្ធម្មប្បញ្ញោ
នៅវត្តលង្កា ក្រុងភ្នំពេញ ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

កោ ឆាតុកសីតិ ឥទំ ធម្មទេសនំ សត្ថា ជេតវនេ វិហរន្តោ វិសាខាយ សហាយិកា សុរាបីតា បញ្ចសតា ឥត្ថិយោ អារព្ភ កថេសិ ។

កាលដែលសម្តេចព្រះសាស្តាចារ្យជាម្ចាស់ ព្រះអង្គទ្រង់សម្រាន្ត ព្រះឥរិយាបថនៅវត្តជេតពន ទ្រង់ប្រារព្ធនូវស្រីប្រាំរយនាក់ ដែលជាសំឡាញ់នឹងនាងវិសាខា ជាស្រីផឹកសុរា ហើយទ្រង់ត្រាស់សំដែងនូវព្រះធម៌ទេសនា មានបទថា កោ ឆាតុកសី ដូច្នេះជាដើម ។

បានឮមកថា: មនុស្សទាំងឡាយលេងមហោស្រព ផឹកសុរាគង់រំពងក្នុងនគរសាវត្ថី, ស្រីៗទាំងប្រាំរយនោះ ចាក់ថែងសុរាជូនស្វាមីដែលកំពុងលេងមហោស្រព រួចស្រេចហើយ ក៏គិតគ្នាថា “ យើងនឹងលេងមហោស្រពដែរ ” ហើយក៏ទៅបបួលនាងវិសាខាៗប្រាប់តបថា: “ មហោស្រពនេះគេលេងផឹកសុរា, ខ្ញុំមិនផឹកសុរាទេ ” ស្រីទាំងនោះនិយាយថា “ សូមនាងថ្វាយទានចំពោះព្រះសម្មាសម្ពុទ្ធចុះ, យើងនឹងលេងមហោ-ស្រព ” ។ នាងវិសាខាទទួលព្រមថា: “ ស្រួលហើយនាង ”, ហើយឲ្យគេនិមន្តសម្តេចព្រះសាស្តាចារ្យមក, នាងថ្វាយមហាទាន, លុះដល់សាយណ្ហសម័យថ្ងៃរសៀល នាងកាន់យកគ្រឿងក្រអូបនឹងផ្កាកម្រងជាច្រើន ស្រីៗទាំងនោះ ក៏ហែហមចោមរោមជាបរិវារ យាត្រាទៅកាន់វត្ត

ដេតពន ដើម្បីស្តាប់នូវធម្មកថា ។ ឯស្រីតាំងនោះទៅឈរទៀបក្លោងទ្វារ ផឹកសុរារួចស្រេចហើយ ទើបចូលទៅគាល់សំណាក់សម្តេចព្រះសាស្តា ជាមួយនឹងនាងវិសាខា ។ ថ្វាយបង្គំសម្តេចព្រះសាស្តាហើយ ក៏អង្គុយនៅក្នុងទីគួរមួយ ។ បណ្តាស្រីតាំងនោះ ស្រីពួកខ្លះរាំ ស្រីពួកខ្លះរាំសាវៃ រាំសដើង កើតជារឿងឈ្មោះប្រកែកក្នុងសំណាក់ព្រះបរមសាស្តាចារ្យ; ព្រះអង្គក៏ទ្រង់បញ្ចេញនូវព្រះរស្មីអំពីព្រះកម្ពុកាលោម (រោមចិញ្ចើម) ដើម្បីឱ្យស្រីតាំងនោះកើតសំវេគតក់ស្លុត ក៏កើតជាអន្ធការងងឹតសព្វទិសានុទិស ។ ស្រីតាំងនោះក៏កើតភ័យខ្លួនតក់ស្លុតមហិមា ដោយសារមរណភ័យមកគម្រាម ។ សុរាក៏សាបរលាបទៅភ្លាម ព្រោះតែភ័យនោះ ។ សម្តេចព្រះដ៏ទ្រង់យស ទ្រង់កៀសចេញអំពីបល្ល័ង្កដែលទ្រង់គង់ ទៅប្រថាប់នៅលើកំពូលភ្នំព្រះសុមេរុ ហើយទ្រង់បញ្ចេញនូវព្រះរស្មីអំពីព្រះឧណ្ណាលោម ( រោមប្រជុំចិញ្ចើម ) ពន្លឺក៏ចែងចាំង ហាក់ដូចជាព្រះចន្ទនឹងព្រះអាទិត្យ ១ ពាន់រះឡើង ។ ព្រះអង្គទ្រង់ប្រថាប់នៅលើកំពូលភ្នំព្រះសុមេរុនោះ ហើយទ្រង់សំដែងនូវបទព្រះគាថា ដើម្បីឱ្យស្រីតាំងនោះកើតសំវេគថា :

កោ នុ ហាសោ កិមានន្ទោ
និច្ចំ បជ្ជលិតេ សតិ ។

កាលបើលោកសន្និវាសនេះ ភ្លើងទាំង ១១ គង[១] ឆេះឡើង សន្ធោសន្ធៅជានិច្ច (យ៉ាងនេះ) តើនាងទាំងឡាយសើចដូចម្តេចកើត? ត្រេកអរដូចម្តេចកើត?

អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ

នាងទាំងឡាយ ពិតជាងងឹតគឺអវិជ្ជាដែលមានវត្ថុ ៨ ប្រការ[២] គ្របសង្កត់ហើយ ម្តេចឡើយក៏មិនស្វែងរកប្រទីបជ្វាលា ពោលគឺប្រាជ្ញា ដើម្បីកំចាត់បង់នូវងងឹតនោះចេញ!

លុះចប់ព្រះគាថាហើយ ស្រីទាំងប្រាំរយនោះ ក៏បានដល់នូវសោតាបត្តិផល ។ សម្តេចព្រះទសពល ទ្រង់និមន្តមកវិញ គង់នៅលើព្រះពុទ្ធាសនៈ ក្រោមម្លប់គន្ធកុដី ។ សម័យនោះ នាងវិសាខាធ្វើវន្ទនាការចំពោះព្រះអង្គរួចស្រេច ក៏ក្រាបបង្គំទូលថា: សូមទ្រង់ព្រះមេត្តាប្រោស, ការផឹកសុរានេះ ជាការទម្លាយនូវហិរិឱត្តប្បៈ (មិនឲ្យមានសេចក្តីអៀនខ្មាសខ្លាចបាប) តើសុរានេះកើតពីត្រឹមណាមកព្រះអង្គ? ទើបទ្រង់នាំអតីតនិទានមកសំដែងប្រាប់នាងវិសាខាថា:

---

១ ភ្លើងគឺ រាគ, ទោស, មោហ, ជាតិ, ជរា, មរណ, សោក, បរិទេវ, ទុក្ខ, ទោមនស្ស, ឧបាយាស ។ ២ មិនដឹងទុក្ខ, មិនដឹងហេតុនៃសេចក្តីទុក្ខ, មិនដឹងសេចក្តីរលត់ទុក្ខ, មិនដឹងផ្លូវនៃសេចក្តីរលត់ទុក្ខ, មិនដឹងអតីត, មិនដឹងអនាគត, មិនដឹងទាំងអតីតទាំងអនាគត, មិនដឹងបដិច្ចសមុប្បាទ ។

អតីតេ កាលេ កាលដែលកន្លងរម្លងទៅហើយ មានព្រះមហាក្សត្រ១ ព្រះអង្គទ្រង់ព្រះនាម ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្រុងពារាណសី (សម័យនោះ) មានថ្នើរព្រៃម្នាក់ឈ្មោះ សុរៈ នៅក្នុងកាសិករដ្ឋ គាត់បានទៅព្រៃហេមពាន្ត ដើម្បីស្វែងរកគ្រឿងគណ្ឋៈផ្សេងៗ នៅព្រៃហេមពាន្តនោះ មានឈើ ១ ដើម ដុះឡើងកំពស់ ១ ជំហរ ហើយបែកប្រគាបជា ៣, ក្នុងចន្លោះប្រគាបទាំង ៣ នោះ មានរណ្តៅទំហំប៉ុនពាង, លុះដល់ទឹកភ្លៀងធ្លាក់មក ក៏ដក់ទឹកពេញក្នុងរណ្តៅនោះ ហើយមានដើមស្រមី កន្ទួតព្រៃ និងម្រេច ដុះជិតរួបរិតដើមឈើនោះ ផ្លែវាទុំជ្រុះធ្លាក់ចុះក្នុងរណ្តៅនោះ, មិនតែប៉ុណ្ណោះ សត្វសេកទាំងឡាយ ក៏គាត់ពាំនាំយកគន្លូវគួរនៃស្រូវសញ្ជាតសាលី អំពីទីជិតខាងមកទំស៊ីនៅលើដើមឈើនោះ គ្រាប់ស្រូវនឹងអង្ករ ក៏ធ្លាក់ចុះក្នុងរណ្តៅនោះទៀត ។ ហេតុដូច្នោះ ទឹកនោះលុះត្រូវកំដៅព្រះអាទិត្យ ក៏មានពណ៌ក្រហមមានរសខ្លាំងឡើង ៗ ក្នុងរដូវសម័យ (រដូវក្តៅ) សត្វបក្សីមានសេចក្តីស្រេកឃ្លាន បានយកផឹកទឹកនោះហើយស្រវឹង បម្រះនទៀល ជ្រប់ដួលដេកនៅទៀបគល់ឈើ, លុះដេកបន្តិចទៅ ក៏ស្រែកកញ្ជ្រៀវខ្សៀវខ្សារ ហើរចៀសចេញទៅ ។ សូម្បីសត្វកំប្រុកនិងស្វាជាដើម ក៏មានទំនងដូច្នោះដែរ ។

នាយថ្មើរព្រៃ បានឃើញទឹកនោះហើយក៏គិតថា "ទឹកនេះ បើជាទឹកពុល, សមជាសត្វទាំងនេះស្លាប់, ប៉ុន្តែសត្វទាំងនេះ គ្រាន់តែដេកបន្តិចហើយក៏ទៅដោយស្រួលទៅ; ទឹកនេះ មិនមែនជាទឹកពុលឡើយ" ទើបគាត់ផឹកខ្លួនឯងក្រៅតែស្រវឹង ហើយមានចំណង់ចង់ស៊ីសាច់, គាត់ក៏បង្កាត់ភ្លើង ហើយសម្លាប់សត្វបក្សីទាំងឡាយ មានទាមាន់ជាដើម ដែលស្រវឹងដួលនៅទៀបគល់ឈើ បំអិនលើរងើកភ្លើង រាំដៃម្ខាង ស៊ីសាច់ដៃម្ខាង នៅក្នុងទីនោះអស់ពីរបីថ្ងៃ ។

សម័យនោះ មានតាបស ១ រូបឈ្មោះ វរុណៈ នៅក្នុងទីជិតនោះ ។ ថ្មើរព្រៃក៏ទៅកាន់សំណាក់តាបសនោះ ហើយក៏គិតថា "បើអញផឹកទឹកនេះជាមួយនឹងតាបស, សមជាសប្បាយណាស់" ទើបគាត់យកទឹកនោះ ១ បំពង់ឫស្សី ជាមួយនឹងជុំសាច់ដែលបំអិនស្រេច ដើរទៅកាន់បណ្ណសាលា ហើយនិយាយថា "សូមលោកម្ចាស់ឆាន់ទឹកនេះលងមើល" តាបសនឹងថ្មើរព្រៃទាំងពីរនាក់ ក៏នាំគ្នាទំពាសាច់ផឹកទឹកនោះ ។ មានឈ្មោះថា ទឹកសុរាផង ទឹកវារុណីផង ព្រោះហេតុដែលថ្មើរព្រៃឈ្មោះ សុរៈ នឹងតាបសឈ្មោះ វរុណៈ បានឃើញមុនគេ ។

អ្នកទាំងពីរគិតគ្នាថា "នេះឯងជាឧបាយដ៏សំខាន់" ហើយក៏ដងដាក់ពេញបំពង់ឫស្សីជាច្រើន រែកទៅកាន់ស្រុកបច្ចន្តគ្រាម, ឲ្យគេ

ក្រាបបង្គំទូលព្រះមហាក្សត្រថា “មានអ្នកបេះធ្វើទឹកស្រវឹងមកហើយ” ។ ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឲ្យហៅអ្នកតាំងពីរនាក់មក; អ្នកតាំងពីរនាក់ ក៏បង្អោនទឹកនោះចូលទៅក្រាបបង្គំថ្វាយ ។ ទ្រង់សោយទឹកស្រានោះពីរបីផងក៏ស្រវឹងមែន ។ ទឹកស្រានោះបានត្រឹមតែ ១ ថ្ងៃ ២ ថ្ងៃ ប៉ុណ្ណោះក៏អស់ទៅ; ទើបទ្រង់ត្រាស់សួរថា “ទឹកស្រានេះមានទៀតទេ?” អ្នកតាំងពីរនាក់ក្រាបបង្គំទូលថា “បពិត្រព្រះសម្មតិទេព, មានទៀត” ។ ទ្រង់ត្រាស់សួរថា “មាននៅឯណា?” អ្នកតាំងពីរនាក់ក្រាបបង្គំទូលថា “បពិត្រព្រះសម្មតិទេព, មាននៅឯព្រៃហេមពាន្ត” ។ ទើបទ្រង់បង្គាប់ថា “បើដូច្នោះ ចូរអ្នកតាំងឡាយទៅយកមកទៀត” ។ ជនតាំងពីរនាក់នោះទៅនាំយកទឹកស្រាមកថ្វាយពីរដងហើយ គិតគ្នាថា “យើងមិនអាចនឹងទៅយកអស់កាលជានិច្ចបានទេ” ហើយក៏ចំណាំគ្រឿងផ្សំគ្រប់មុខបាន យកមកធ្វើស្រានៅក្នុងព្រះនគរ ។ អ្នកនគរតាំងនោះនាំគ្នាផឹកស្រា ហើយក៏ប្រែទៅជាអ្នកមានសេចក្ដីប្រមាទ ប្រហែសធ្វេសក្នុងការងារ ត្រឡប់ទៅជាអ្នកកំសត់ទុគ៌ត ។ ព្រះនគរក៏ហាក់ដូចជាសូន្យ ឥតមានមនុស្ស ឥតមានសេចក្ដីចំរើនដោយការងារណាមួយឡើយ ។ ហេតុដូច្នោះ បានជាអ្នកធ្វើស្រានាំគ្នារត់ចេញអំពីទីនោះ ទៅកាន់នគរពារាណសី, ឲ្យគេក្រាបបង្គំទូលសម្ដេចព្រះនរបតីថា “មានអ្នកធ្វើស្រាមកដល់ហើយ” ។ ព្រះរាជា

ទ្រង់បញ្ជាឲ្យហៅមក ហើយទ្រង់ព្រះរាជទានស្បៀងដើមទុនឲ្យធ្វើស្រា ដូច្នោះទៀត ។ នគរនោះក៏វិនាសដូចនគរមុនទៀត ។ អ្នកធ្វើស្រាទាំងពីរនាក់ រត់ចេញអំពីនគរពារាណសី ទៅកាន់នគរសាកេត, រត់ចេញអំពីនគរសាកេត ទៅកាន់នគរសាវត្ថី ។ គ្រានោះ, ព្រះចៅក្រុងសាវត្ថីទ្រង់ព្រះនាមព្រះបាទសព្វមិត្ត ព្រះអង្គទ្រង់ធ្វើសេចក្តីសង្គ្រោះដល់អ្នកទាំងពីរនាក់នោះ ទ្រង់មានព្រះរាជឱង្ការសួរថា "អ្នកទាំងឡាយត្រូវការវត្ថុអ្វីខ្លះ?" អ្នកធ្វើស្រាក្រាបបង្គំទូលថា "ទូលព្រះបង្គំជាខ្ញុំត្រូវការថ្នូរគ្រឿងផ្សំ និងមេស្រា ស្រូវសាលី ហើយនិងផ្ទឹន(១)ចំនួនប្រាំរយ" ។ ព្រះរាជាក៏ព្រះរាជទានវត្ថុគ្រប់មុខ តាមសេចក្តីត្រូវការ ។ អ្នកធ្វើស្រាទាំងនោះដាក់ស្រាក្នុងផ្ទឹនទាំងប្រាំរយ ហើយខ្លាចក្រែងកណ្តុរចូល ក៏ចងឆ្មាមួយ ១ ជិតផ្ទឹនមួយ ១ ។ ឆ្មាទាំងនោះផឹកស្រាដែលហៀរចេញអំពីផ្ទឹន ហើយស្រវឹងដេកលក់អស់ទៅ ។ ពួកកណ្តុរមកដល់ហើយ ក៏កកេរស៊ីត្រចៀក ច្រមុះ បង្កួយ និងកន្ទុយឆ្មាទាំងនោះរេចអស់ ហើយទៅបាត់ទៅ ។

ពួកអាយុត្តកបុរស នាំសេចក្តីទៅក្រាបបង្គំទូលព្រះមហាក្សត្រថា "ឆ្មាទាំងឡាយផឹកស្រាពុលស្លាប់អស់ទៅហើយ" ។ ព្រះរាជាក៏ទ្រង់ព្រះពិរោធឡើងថា "យីអើ! វាទាំងនេះជាអ្នកធ្វើថ្នាំពុលទេតើ" ។ ហើយទ្រង់

១ ឬគណហៅថា ពាង ប៉ូវ កប៉ុក សម្រាប់បិទស្រា។

បង្គាប់ឲ្យគាត់ក្បាលជនទាំងពីរនាក់ៗ ផឹកសុរាហើយក៏ស្រែកថា "បពិត្រព្រះសម្មតិទេព, ទឹកឆ្ងាញ់ៗ" ដូច្នេះ ដរាបតែស្លាប់ទៅទើបបាត់មាត់ៗ ព្រះរាជាទ្រង់បង្គាប់ឲ្យសម្លាប់អ្នកទាំងពីរនោះហើយ ឲ្យចំលាយទាំងផ្ទឹនថែមទៀត ៗ លុះសុរាសាបហើយ, ឆ្មាំទាំងឡាយក៏គ្រោកឡើងលោតលេងហក់កញ្ឆេងកញ្ឆៀវគ្នា; ទើបពួកអាយុត្តកបុរស នាំសេចក្ដីទៅក្រាបបង្គំទូលព្រះរាជាៗ ទ្រង់ព្រះចិន្តាការថា "បើទឹកនោះជាវត្ថុពុលស័យជាឆ្មាំទាំងនោះស្លាប់; ទឹកនោះប្រហែលជាមានរសឆ្ងាញ់ពិតមែនទេដឹង, បើដូច្នេះ អញផឹកលងមើលអេះ" ហើយទ្រង់បង្គាប់ឲ្យរាជសេវកាមាត្យទាំងឡាយរៀបចំប្រដាប់តែងព្រះនគរ ឲ្យធ្វើបាពំមណ្ឌបក្នុងព្រះរាជលាន ហើយទ្រង់ឡើងគង់លើព្រះរាជបល្ល័ង្ក ក្រោមស្វេតច្ឆត្រក្នុងមណ្ឌបដែលប្រដាប់តុបតែងដោយគ្រឿងអលង្ការមហាប្រសើរ មានពពួកអាមាត្យហោមរោមជាបរិវារ ព្រះអង្គប្រុងប្រៀបនឹងសោយសុរា ៗ

គ្រានោះ សម្ដេចសក្កទេវរាជ ទ្រង់ប្រមើលមើលនូវសត្វលោកថា "នរណាខ្លះហ្ន៎! ជាអ្នកមិនប្រហែសក្នុងកុសលធម៌ទាំងឡាយ មានការបម្រើនូវមាតានឹងបិតាជាដើម; អ្នកណាខ្លះហ្ន៎! ជាអ្នកបំពេញនូវសុចរិតទាំង៣" ៗ សម្ដេចសហស្សន័យក៏បានឃើញនូវព្រះបាទសព្វមិត្ត

កំពុងតែគង់ប្រុងប្រៀបនឹងសោយសុរា ព្រះអង្គទ្រង់ព្រះចិន្តានាការថា "បើព្រះបាទសព្វមិត្តនេះសោយសុរា, មុខជាអ្នកជម្ពូទ្វីបទាំងអស់នឹងវិនាស, បើដូច្នោះ មានតែអញនឹងធ្វើស្តេចនោះកុំឲ្យសោយសុរាបានអេះ" ហើយទ្រង់កាន់យកក្អមមួយ ដាក់សុរាពេញ ក្លែងភេទជាព្រាហ្មណ៍មកស្ថិតនៅឰដ៏អាកាស ក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ហើយពពាយនាយថា "អ្នកទាំងឡាយចូរទិញក្អមនេះចុះ, អ្នកទាំងឡាយចូរទិញក្អមនេះចុះ" ។ ព្រះបាទសព្វមិត្ត ទ្រង់ទស្សនាការឃើញនូវព្រាហ្មណ៍នោះស្ថិតនៅឰដ៏អាកាស និយាយដូច្នោះ ក៏ទ្រង់មានព្រះរាជឱង្ការ បរបាជាមួយនឹងព្រាហ្មណ៍នោះថា "ព្រាហ្មណ៍ឯងទើបមកពីណាហ្នឹង?" ហើយទ្រង់ពោលបទព្រះគាថា ៣ ព្រះគាថាដូច្នេះថា :

១- កោ បាតុរាសី តិទិវា នភម្ហិ
ឱភាសយំ សំវរឹ ចន្ទិមាវ
គត្តេហិ តេ រស្មិយោ និច្ឆរន្តិ
សតេរតា[១] វិជ្ជុរិវន្តលិក្ខេ ។

អ្នកឯងមកពីណា អ្នកមកអំពីភពត្រៃត្រឹង្ស ឬ កើតនៅក្នុងអាកាសនេះទេ គឺបំភ្លឺភពត្រឹមឲ្យស្វាងរុងរឿង ដូចជាព្រះចន្ទ្រផលុំម៉ុះ? រស្មីនៃអ្នក

១ ឧភេបិយពោត្ថកេ សតេរតា ឥតោ ។

ដែលផ្សាយចេញអំពីខ្លួន ហាក់ដូចជាផ្លេកបន្ទោរឈ្មោះ សតេរតា ដែលលេចឡើងក្នុងកណ្ដាលអាកាស ។

២ - សោ ឆិន្នភត្តំ កមសី អយុទ្ធិ
វេហាសយំ គច្ឆសិ តិដ្ឋសី ច
ឥទ្ធី នុ តេ វត្ថុកតា សុភាវិតា
អនទ្ធគូនម្បិ[១] ទេវតានំ ។

អ្នកឯងឥតមានខ្យល់ប៉ុនឡើងទេ, ប៉ុន្តែប្រព្រឹត្តទៅក្នុងអាកាសដ៏វាលល្វឹងបាន; អ្នកឯងទៅ ឬ ស្ថិតនៅក្នុងអាកាសវេហាស៍ក៏បាន; រិទ្ធិដែលអ្នកឯងធ្វើឲ្យជាទីតាំង (របស់ខ្លួន) ដែលអ្នកឯងចំរើនហើយដោយល្អ (ហាក់ដូចជាមិនមែនរិទ្ធិរបស់មនុស្ស) ប្រហែលជារិទ្ធិរបស់ទេវតាដែលជាអ្នកមិនដែលដើរដើនទៅកាន់ផ្លូវឆ្ងាយទេដឹង[២] ។

៣ - វេហាសយំ កាមមាគម្ម[៣] តិដ្ឋសិ
កុម្ភំ កិណោ ជាតិ យមេតមត្ថំ
កោ វា តុវំ កិស្សវតាយ កុម្ភោ
អក្ខាហិ មេ ព្រាហ្មណ ឯតមត្ថំ ។

---

១ ឧក្រោបិយពោត្តកេ អនទ្ធគូនំ អបិ ។ ២ ទេវតាទាំងឡាយដែលមានដំណើរទៅកាន់ទីឆ្ងាយ រមែងហោះទៅតាមអាកាស ។ ៣ ឧក្រោបិយពោត្តកេ សន្តិមាគម្ម ឆាលោ ។

អ្នកឯងឈានទៅក្នុងអាកាសវេហាស៍ ហើយឈរពោលពាយ នាយថា “អ្នកតាំងឡាយចូរចេញក្អមចុះ, តើអ្នកឯងឈ្មោះអ្វី? ម្យ៉ាងទៀត ក្អមនេះជាក្អមអ្វី? ម្នាលព្រាហ្មណ៍, អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ។

លំដាប់នោះ សម្តេចសក្កទេវរាជ បានទ្រង់ព្រះសវនាការហើយ ទ្រង់មានព្រះបន្ទូលថា “បើដូច្នោះ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ចុះ” ហើយទ្រង់សំដែងនូវទោសសុរាថា :

៨- ន សប្បិ កុម្ភោ នបិ តេលកុម្ភោ
ន ផាណិតស្ស ន មធុស្ស កុម្ភោ,
កុម្ភស្ស វជ្ជានិ អនប្បកានិ,
ទោសេ ពហូ កុម្ភគតេ សុណាថ ។

ក្អមនេះ មិនមែនក្អមសប្បិ មិនមែនក្អមប្រេង មិនមែនក្អមស្ករអំពៅ មិនមែនក្អមទឹកឃ្មុំទេ, ទោសរបស់ក្អមនេះ មានច្រើនប្រការ, សូមព្រះករុណាទ្រង់ព្រះសវនាការនូវទោសដ៏ច្រើន ដែលមាននៅក្នុងក្អមនេះចុះ ។

៩- គលេយ្យ យំ បិត្វា, បតេបបាតំ
សោព្ភំ គុហំ ចន្ទនិយោលិគល្លំ,
ពហុំបិ កុញ្ជេយ្យំ អភោជនេយ្យំ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកផងផឹកនូវស្រា ហើយដើរផ្លូវសស្រូស, ភ្លាក់ចុះក្នុងផ្លុក ក្នុងអណ្ដូង ក្នុងរូង ក្នុងរណ្ដៅជ្រាំ ក្នុងអន្លង់, ហើយត្រូវការបរិភោគតែអាហារដែលមិនគួរបរិភោគជាច្រើន; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយស្រានោះចុះ ។

៦- យំ វេ[១] បិត្វា ចិត្តស្មិំ អនេសមានោ
អាហិណ្ឌតី គោរិវ ភក្ខសាទី[២]
អនាថមានោ ឧបគាយតិ នច្ចតិ ច;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកផងផឹកនូវស្រា ហើយមិនបានដាក់ស្មារតីលើចិត្ត (ចិត្តគិតយ៉ាងណា ក៏ប្រព្រឹត្តតាមកិរិយាដូច្នោះ ឥតមានប្រាជ្ញាជាគ្រឿងទប់ទល់ឡើយ), ដូចជាគោដែលស៊ីបាយស្ងួត, តែស៊ីហើយកាលណា តែងជ្រេកមមកស្វែងរកអាហារក្នុងទីតែផ្លាស អ្នកប្រមឹកនោះ ជាមនុស្សគ្មានទីពឹង បើបានឮគេច្រៀង ក៏ចូលទៅច្រៀងផង បានឃើញគេរាំ ក៏ចូលទៅរាំផង អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយស្រានោះចុះ ។

៧- យំ វេ បិត្វា អចេលកោវ នគ្គោ
ចរេយ្យ គាមេ វិសិខន្តរានិ

១ ឧភោសុបិ យមកបោត្ថកេ វេសទ្ទោ ន ទិស្សតិ ។ ២ ឧភោសុបិ យមកបោត្ថកេ ភក្ខសាទិតិ ។

សមុប្លចិត្តោ អតិវេលសាយី(១);

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកដែលផឹកនូវសុរាហើយ ( ភ្លេចបិទបាំងកេរ្តិ៍ខ្មាស ) ជាមនុស្សអាក្រាតដូចជាអចេលកៈ ហើយក្រាបទៅពាសស្រុកពាសផ្លូវថ្នល់ ជាមនុស្សមានចិត្តផ្អើលផ្អាល ដេកដើរហួសវេលា; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

៨- យំ វេ បិត្វា ឧដ្ឋាយ បវេធមានោ

សីសញ្ច ពាហុញ្ច បចាលយន្តោ

សោ នច្ចតី ទារុកដល្លកោវ;

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកនូវសុរា ហើយក្រោកឡើងដើរផ្ទួលផ្ទួស ងក់ក្បាល ត្កាដៃ រាំរែក ( ទៅតាមតែបានឥតមានទំនួល ) ហាក់ដូចជារូបយន្តដែលធ្វើដោយឈើ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

៩ យំ វេ បិត្វា អគ្គិទឌ្ឍា សយន្តិ

អថោ សិង្គាលេហិបិ ខាទិតាសេ

ពន្ធំ វធំ ភោគជានិញ្ចុបេន្តិ;

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

១ អតិវេលចារីតិបិ ឆាហេ ។ ( អដ្ឋកថា ) ។

ជនទាំងឡាយផឹកនូវសុរា ហើយមានសេចក្ដីក្ដៅក្រហាយដូចជាភ្លើងឆេះ ដេកនៅក្នុងទីតែផ្កាស, សត្វទាំងឡាយមានបបកជាដើម ចិកាស៊ីក៏មាន ប្រព្រឹត្តអនាចារផ្សេងៗ មានវាយ កាប់ និងសម្លាប់គេជាដើម ដោយតែកផងការចាប់ចងនាំទៅសម្លាប់ ឬ រឹបជាន់ទ្រព្យសម្បត្តិអស់ទៅក៏មាន; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១០- យំ វេ បិត្វា ភាសេយ្យ អភាសនេយ្យំ,
សភាយមាសិនោ អបេតវត្ថោ
សមក្ខិតោ វន្តគតោ ព្យសន្នោ;
តស្ស បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកផងផឹកនូវសុរា ហើយពោលនូវពំនោល ដែលគេមិនគប្បីពោល, ចុះជាអង្គុយនៅក្នុងទីជាទីប្រជុំ ក៏អាក្រាតសំពត់អាវ (មិនដឹងខ្លួន) ជាមនុស្សមានគ្រឿងក្អួតទន់ព្រើម ក្រាំនៅក្នុងកំអួតរបស់ខ្លួន ហើយដល់នូវសេចក្ដីវិនាសផ្សេងៗ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១១ យំ វេ បិត្វា ឱក្កដ្ឋា អាវិលនេត្តា
មមេវ សព្វបថវីតិ (១) មញ្ញតិ (២),

---

១ សព្វបឋវីបិ ជាបាឋ ( អដ្ឋកថា ) ។ ២ ឱ មញ្ញ ។

ពុទ្ធសាសនបណ្ឌិត BUDDHIST INSTITUTE LIBRARY

ន មេ សមោ ជាតុរដ្ឋេ ជនា;

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកផឹកនូវសុរា ហើយក្អេងក្អាងអួតអាងថា ខ្ញុំជាអ្នកពាហានហានក្លា ឥតមានអ្នកណាស្មើនឹងខ្ញុំឡើយ ជាមនុស្សមានភ្នែកក្រហមជានិច្ច តែងមានសេចក្តីសំគាល់មើលងាយថា ផែនដីទាំងមូលជារបស់អញ ទុកជាស្តេចដែលជាឥស្សរៈលើផែនដី មានព្រំប្រទល់ដល់សមុទ្រទាំងបួន ក៏នៅតែមិនស្មើនឹងអញដែរ ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១២ - មាតាតិមាតា កាលបាធិ បេសុណំ[1]

ទុព្វណ្ណិនី នគ្គិយិនី បលាយិនី,

ធោភណា ទុត្តាន[2] គតី និគេតា;

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកនូវសុរា ហើយធ្វើនូវជាមោះ ព្រោះសេចក្តីមើលងាយគេ ជាមនុស្សបេះបួយពោលពាក្យញុះញង់ ដើម្បីបំបែកបំបាក់គេ ជាមនុស្សមានសម្បុរគគ្រក់ អាក្រាក់ជាប្រក្រតី ហើផ្លូនជាខ្ញាបខ្ញី គេតែងតែមើលគិត ឯលំនៅរបស់ជនទាំងនោះ សុទ្ធតែជាទី ប្រទូនេនតួអ្នកលេងតាស់ ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

---

១ ឧភោបិយធោត្តក បេសុណកាន់ ។ ២ ឧភោបិយធោត្តក ធោភន់ ទុត្តាន់ ។

១៣ - ឥទ្ធានិ ផីតានិ កុលានិ អស្សុ
អនេកសាហស្សធនានិ លោកេ,
ឧច្ឆិន្នទាយជ្ជកតានិយាយ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ៗ

ត្រកូលដែលសម្រឹទ្ធិបរិបូណ៌ដោយវត្ថាលង្ការ និងប្រដាប់ប្រដាផ្សេងៗ មានធនធានជាច្រើនពាន់, គេធ្វើត្រកូលដូច្នោះ ឲ្យអស់កេរ្តិ៍អាកររលីងទៅ ព្រោះតែសុរានេះ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ៗ

១៤ - ធញ្ញំ ធនំ រជតំ ជាតរូបំ
ខេត្តំ គវំ យត្ថ វិនាសយន្តិ,
ឧច្ឆេទនី វិត្តវតំ កុលានំ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ៗ

ជនទាំងឡាយបំផ្លាញនូវសម្បត្តិផ្សេងៗ មានស្រូវ ទ្រព្យ ប្រាក់ មាស ស្រែ និងគោជាដើម ឲ្យវិនាសទៅក្តី, ជាអ្នកផ្តិលផ្តាច់វង្សត្រកូល ដែលធ្លាប់ប្រព្រឹត្តទៅកាន់សេចក្តីចំរើន ឲ្យធ្លាក់ចុះទៅកាន់សេចក្តីវិនាសក្តី ព្រោះតែសុរាឯណា; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ៗ

១៥- យំ វេ[១] បិត្វា ទុដ្ឋរូបោ[២] ហោសោ

អក្កោសតិ បិតរំ មាតរញ្ច,

សស្សុ[៣] គណ្ហេយ្យ អថោបិ សុណ្ហំ;

តស្ស បុណ្ណំ កុម្ភមិមំ កិណាថ ។

មនុស្សប្រុសស្លូតបូតសោះទេ តែបើបានផឹកសុរាហើយ ក៏ត្រឡប់ក្លាយជាមនុស្សរពឹសរពើស ហ៊ានជេរប្រទេចផ្តាសាបិតាមាតា, បើមានម្តាយក្មេក ហ៊ានចាប់ម្តាយក្មេក បើមានកូនប្រសា ហ៊ានចាប់កូនប្រសាសំគាល់ថាជាភរិយារបស់ខ្លួន; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១៦- យំ វេ បិត្វា ទុដ្ឋរូបា នារី

អក្កោសតិ សស្សុរំ សាមិកញ្ច,

ទាសំបិ គណ្ហេ បរិចារិកម្បិ;

តស្ស បុណ្ណំ កុម្ភមិមំ កិណាថ ។

មនុស្សស្រីស្លូតបូតសោះទេ តែបើបានផឹកសុរាហើយ ក៏ត្រឡប់ក្លាយជាមនុស្សរពឹសរពើស ហ៊ានជេរប្រទេចផ្តាសាឪពុកក្មេក ឬ ស្វាមី ក៏ប្រឡូកចាប់ខ្ញុំកំដរ សំគាល់ថាជាស្វាមីរបស់ខ្លួន; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

---

១ ខ ភេបិយ គោត្តកេ យតៀ បិត្វា ។ ២ ខ ទុដ្ឋរូបោ ។ ៣ ខ សស្សុំបិ ។

១៧ - យំ វេ បិត្វាន ហនេយ្យ បោសោ

ធម្មេ ឋិតំ សមណំ ព្រាហ្មណំ វា,

គច្ឆេ អបាយំបិ គតោតិធាធំ;

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនប្រុសស្រីផឹកសុរាហើយ ហ៊ានសម្លាប់សមណៈ ឬ ព្រាហ្មណ៍ ដែលស្ថិតនៅក្នុងសុចរិតធម៌, ក៏ធ្លាក់ទៅកើតក្នុងអបាយភូមិគឺៈ នរក ប្រេត អសុរកាយ តិរច្ឆាន ព្រោះតែការសម្លាប់សមណៈ ឬ ព្រាហ្មណ៍នោះ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយ សុរានោះចុះ ។

១៨ - យំ វេ បិត្វា ទុច្ចរិតំ ចរន្តិ

កាយេន វាចាយ ច ចេតសា វា.

និរយំ វជន្តិ ទុច្ចរិតំ ចរិត្វា;

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកសុរាហើយ ប្រព្រឹត្តនូវទុច្ចរិត ដោយកាយ ដោយ វាចា ឬ ដោយចិត្ត, លុះប្រព្រឹត្តទុច្ចរិតគឺធ្វើអកុសលទាំង ១០ ប្រការ ដោយ ទ្វារទាំង ៣ យ៉ាងនេះហើយ ក៏ធ្លាក់ចុះទៅកើតក្នុងនរក, អ្នកទាំងឡាយ ចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១៩- យំ យាចមានា ន លភន្តិ បុត្តេ
ពហុំ ហិរញ្ញំបិ បរិច្ចជន្តា,
សោ តំ បិវិត្វា អសតំ ភណាតិ;
តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុរសស្ត្រីទាំងឡាយឯណា កាលដើមឡើយ ជាមនុស្សពោលពាក្យសត្យប្រាកដប្រជា ទុកជានរណាមួយឲ្យប្រាក់សំណូកជាច្រើន ហើយអង្វរគេថា "សូមអ្នកនិយាយកុហកបន្តិចចុះ" ដូច្នេះ ក៏នៅតែមិនបាន លុះបុរសស្ត្រីនោះ បានផឹកសុរាវេលាណា ក៏រមែងពោលពាក្យលេះលោះមិនសមហេតុ-ផល តាំងពីវេលានោះមក; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២០- យំ វេ បិត្វា បេសរោ[១] បេសុយន្តោ[២]
អប្បាយិកោ តារិយម្ភិ ជាតេ[៣],
អត្តម្បិ សោ ឧបវាធាតិ វុត្តោ;
តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

កាលបើមានគ្នារួសរាន់កើតឡើង, គេប្រើប្រែសណ្ឋិយបុរស (បុរសដើរសារ) ដែលផឹកសុរាឲ្យទៅ ដើម្បីបញ្ជាក់សេចក្តីដល់អ្នក

---

១ ឧភោបិយវោហារកេ បរិត្តា បេសនេ បេសិយនោតិ ឥតិបិ ។ ២ ខ បេសិយន្តោ។
៣ ខ ជាតោតិ ឥតិបិ, សោ ឧ យុត្តោ ។

ឯណោះ អ្នកឯណោះសួរថា: អ្នកឯងមកមានការអ្វី ? វាក៏មិនដឹងសេចក្ដីអ្វីសោះ ព្រោះស្រវឹងសុរាស្ដាប់ពាក្យបណ្ដាំមិនបាន ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

៤១ ហិរីមតា អហិរីកាការំ

ចាតុំ គាកេត្តិ មនុជាយ(១) មត្តា,

ជីវាមិ សត្តា ពហុកំ កណន្តិ;

តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយ ទុកជាមានចិត្តប្រកបដោយហិរិ សេចក្ដីអៀនខ្មាស យ៉ាងណាក៏ដោយ តែស្រវឹងសុរាហើយ ក៏រមែងធ្វើនូវភាពនៃខ្លួនជាមនុស្សមិនមានហិរិ ឲ្យប្រាកដជាក់ស្ដែងដល់ភ្នែកអ្នកទាំងពួង, ឯលោកអ្នកប្រាជ្ញទាំងឡាយជាសប្បុរស មានសន្ដានស្ងប់ស្ងាប់ រមែងពោលពាក្យដ៏ងៀលជាច្រើន, អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

៤២ យំ វេ បិត្វា បកត្ថូជា សយន្តិ

អនាសកា ថណ្ឌិលទុក្ខសេយ្យំ(២)

ទុព្ភណ្ណិយំ អាសយកញ្ញាបេន្តិ(៣);

តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

---

១ ឱ. មនុជាយកតិ ញាយោ ។ ២ [illegible] ។ ៣ ឱ. អាយសក្កញ្ញបេន្តិ ។

មនុស្សទាំងឡាយដ៏ថ្លៃថ្លា កាលបើផឹកសុរាហើយ រមែងដេកប្រគាត់ប្រគងប្រគន្លា ទាំងមនុស្សមានជាតិថោកទាបដូចជាកូនជ្រូក, ទុកជាកាលពីដើមជាមនុស្សបរិបូណ៌ដោយភោជនាហារ ទាំងទីលំនៅ ក៏ត្រឡប់ទៅជាមនុស្សឥតអាហារ ដេកកើតទុក្ខលើផែនដី ជនប្រុសស្រីរមែងថ្លែងសេចក្ដីសង្វេគដ៏អាក្រក់ៗ, គេតែងតិះដៀល ដោយដំនៀលផ្សេងៗ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២៣- យំ វេ បិត្វា បត្តត្ថា សយន្តិ
តាវេ ក្រុធហាតារំ, ន ហិ
ភុណ្ហិយា វោគា ឥរេន សុស្សយោរំ;
តស្ស បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកសុរាហើយ រមែងទន់ភ្លន់ផ្ទៀតដេកទៅ ដូចជាគោដែលមនុស្សកំណាចកាត់ដោយខ្សែព្រួញហើយនាំទៅ រមិនស៊ីស្មៅ មិនផឹកទឹក ដូច្នោះឯង, ឯកម្លាំងសុរា ឥតមាននរណាប្រឹងប្រែងទប់ទល់បានឡើយ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២៤- យំ មនុស្សា វិវជ្ជន្តិ សព្វំ
ឃោរំវិសម៉ំ, តំ លោកេ វិសសមានំ

គោ ឧកេ ចាតុមហារតិ;

តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

មនុស្សទាំងឡាយ ដែលជាអ្នកដឹងសេចក្តីខុសត្រូវ រមែងវៀរលែងនូវស្រា ដូចជាគេវៀសវាងសត្វពស់មានពិសដ៏ពន្លឹក, នរណាហ្ន៎ ទើបគួរដើម្បីផឹកនូវស្រានោះ ដែលប្រហែលគ្នានឹងពស់មានពិសក្នុងលោកដូច្នោះ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយស្រានោះចុះ ។

២៥ - យំ វេ បិត្វា អន្ធកាវេណ្ហុបុត្តា[១]

សមុទ្ទតីរេ បរិចារយន្តា

ឧបក្កមុំ មុសលេហិ អញ្ញមញ្ញំ,

តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

កាលពីដើម មានព្រះរាជបុត្តក្សត្រជាបងប្អូននឹងគ្នា ១០ ព្រះអង្គ កាលដែលពួករាជសេវកៈកំពុងបម្រើ នៅទៀបឆ្នេរសមុទ្រ ក៏ទ្រង់ប្រហារគ្នានឹងអង្រែទៅវិញទៅមក ព្រោះតែផឹកនូវស្រាឯណា, អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយស្រានោះចុះ ។

២៦ - យំ វេ បិត្វា បុព្វទេវា បមត្តា

តិទិវា ចុតា សស្សតិយា សមាយា,

---

១ ន អន្ធកវិណ្ហុបុត្តា ។

តំ តាទិសំ មជ្ឈមិទំ និរត្ថកំ

ជានំ មហារាជ តវំ វិវជ្ជយ ។

ពួកអសុរទាំងឡាយ មានសេចក្តីប្រមាទហើយ ច្យុតចាកតាវតឹង្ស ទេវលោក ដែលលោកសន្មតថាជាទីទៀង ព្រោះមិនសូវប្រែប្រួលដោយសេចក្តីស្លាប់កើត ធ្លាក់មកព្រមទាំងពួកអសុរមាយាស្នួមស្រីផ្ការផង ព្រោះតែផឹកនូវសុរាឯណា, បពិត្រមហាពរ បណ្ឌិតបុរសជាអ្នកមានប្រាជ្ញាប្រហែលព្រះអង្គ កាលបើជ្រាបថា សុរានោះជាទឹកឥតប្រយោជន៍ យ៉ាងនេះហើយ នឹងសោយសុរានោះដូចម្តេចកើត !

២៧- នយិមស្មិំ កុម្ភស្មិំ ទធិ មធុ វា

យំ អភិញ្ញាយ កិណាហិ ភទ្ទ,

យថាតថំ កុម្ភគតា[1] មយា តេ

អក្ខាតរូបំ តវ សព្វមិត្តាតិ ។

ទធិក្តី ទឹកឃ្មុំក្តី មិនមានក្នុងក្អមនេះទេ, បពិត្រព្រះរាជា ព្រះអង្គបានជ្រាបច្បាស់យ៉ាងនេះហើយ សូមទិញក្អមនេះចុះ, ឯទោសដែលមាននៅក្នុងក្អមរបស់ខ្ញុំយ៉ាងនេះ ខ្ញុំបានថ្លែងថ្វាយព្រះអង្គសព្វគ្រប់ហើយ, បពិត្រព្រះបាទសព្វមិត្ត ពាក្យដែលខ្ញុំបានពោលថ្វាយព្រះអង្គ ជាពាក្យពោលតាមសេចក្តីពិត ។

---

១ កុម្ភគតា មយាតិ កុម្ភគតំ មយាតិ អយមេវ វា បាឋោ ។ (អដ្ឋកថា) ។

ព្រះមហាក្សត្រ បានទ្រង់ព្រះសវនាការសេចក្តីនោះសព្វគ្រប់ហើយ ទ្រង់ជ្រាបច្បាស់នូវទោសនៃសុរា ទ្រង់មានព្រះទ័យត្រេកអរ ទ្រង់ធ្វើជាមនាការ សរសើរសម្តេចសក្កទេវរាជ ពោលព្រះគាថា២ព្រះគាថាដូច្នេះថា :

២៨- ន មេ បិតា វា អថ វាបិ មាតា
ឯតាទិសោ យាទិសកោ តុវំសិ
ហិតានុកម្បី បរមត្ថកាមោ
សោហំ ករិស្សំ វចនំ តវជ្ជ ។

២៩- ទទាមិ តេ គាមវរានិ បញ្ច
ទាសីសតំ សត្ត គវំសតានិ
អាជញ្ញយុត្តេ ច រថេ ទសា ឥមេ,
អាចរិយោ ហោសិ មមត្ថកាមោតិ ។

អ្នកឯងនេះ ជាបិតា ឬ ជាមាតារបស់ខ្ញុំក៏ទេដែរ, ប៉ុន្តែជាអ្នកអនុគ្រោះខ្ញុំដោយពាក្យសំដីដ៏មានប្រយោជន៍ ជាអ្នកប្រាថ្នានូវប្រយោជន៍ដ៏ឧត្តមដល់ខ្ញុំ, តាំងពីថ្ងៃនេះតទៅ ខ្ញុំនឹងធ្វើតាមពាក្យអ្នក ៗ ឥឡូវនេះ ខ្ញុំសូមជូនស្រុកសួយប្រាំកន្លែង ដែលមានសួយឡើង ១ សែនៗក្នុង ១ ឆ្នាំៗ នឹងខ្ញុំស្រី ១ រយ គោ ៧ រយ រាជរថដែលទឹមដោយសេះអាជានេយ្យ ១ គូៗ

ទាំង ១០ មុខ(១) នេះដល់អ្នកឯង, អ្នកឯងប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ សូមតាំងខ្លួនជាគ្រូអាចារ្យខ្ញុំចុះ ។

សម្តេចសក្កទេវរាជ បានទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ក៏សំដែងនូវអត្តភាពជាទេវតាវិញ ឲ្យព្រះរាជាស្គាល់ខ្លួន ហើយស្ថិតនៅក្នុងអាកាស ទ្រង់ពោលព្រះគាថា ២ ព្រះគាថាដូច្នេះថា :

៣០- ទទេវ ទាសីសតមត្ថុ រាជ,
គាមា ច គាវោ ច ទទេវ យោគ្គ
អាជញ្ញយុត្តា ច រថា ទទេវ,
សក្កោហមស្មិ តិទសានមិន្ទោ ។

៣១- មំសោធនំ សព្វិទាយត្វ កុញ្ញេ(២)
ទានស្សុ ច ត្វំ មធុមាសព្វេ,
ឃរំ តុវំ ធម្មរតោ ជនិន្ទ
អនិន្ទិតោ សគ្គមុបេហិ ឋានន្តិ ។

បពិត្រព្រះរាជា ទាសីទាំង ១ រយ សូមជារបស់ព្រះអង្គវិញចុះ, ស្រុកទាំងឡាយក្តី គោទាំងឡាយក្តី ក៏សូមជារបស់ព្រះអង្គវិញចុះ, ទាំងរថដែលទឹមដោយសេះអាជានេយ្យ ក៏ខ្ញុំសូមថ្វាយព្រះអង្គវិញដែរ, ខ្លួនខ្ញុំឈ្មោះសក្ក ជាឥន្ទ្រាធិបតីនៃទេវតាក្នុងពិភពតាវត្រឹង្ស មិនសំឡឹងចង់បានសម្បត្តិរបស់ព្រះអង្គប៉ុណ្ណោះទេ ។ សូមតែព្រះអង្គកុំសោយសុក សូម

---

១ ក្នុងបាលីថា វត្ថុ ១០មុខ ប៉ុន្តែរាប់បានតែ ៤ មុខ ។ ២ ៖ កុញ្ញ ។

ក្សត្រទ្រង់សោយតែក្រយាស្ងោយ ដែលប្រកបដោយម្ហូបតាមធម្មតា នឹងទឹកសប្បីវិញ; បើសត្វព្រះទ័យចំណីឈ្ងុយឆ្ងាញ់ សូមព្រះអង្គទ្រង់សោយនំសណ្តែក ដែលលាយដោយទឹកឃ្មុំចុះ, បពិត្រព្រះជនិន្ទពិនភាព បើព្រះរាជាវៀរបង់មិនទ្រង់សោយសុរា ហើយក្សត្រាទ្រង់សោយតែព្រះ-ស្ងោយ ដែលមានសេដ្ឋប្រសើរផ្សេងៗ ទ្រង់លះលែងទុច្ចរិតទាំង ៣ មានព្រះទ័យត្រេកអរចំពោះសុចរិតធម៌ទាំង ៣ ប្រការយ៉ាងនេះហើយ ឥតមាននរណានិន្ទាព្រះអង្គបានឡើយ ហើយព្រះអង្គនឹងបានទៅកើតក្នុងស្ថានសួគ៌ទៀត ។

សម្តេចសក្កទេវរាជ ទ្រង់ប្រទានឱវាទដល់ព្រះបាទសត្វមិត្តនោះដូច្នោះហើយ ក៏ត្រឡប់ទៅលំនៅរបស់ព្រះអង្គវិញ ។

ឯព្រះបាទសត្វមិត្តនោះវិញ ក៏ឈប់សោយសុរា ក្សត្រាទ្រង់ឲ្យចម្ងាយភាជនៈសម្រាប់ដាក់សុរាចេញអស់ ហើយទ្រង់សមាទានសីល៥ សីល៨ បត្រីទ្រង់បរិច្ចាគព្រះរាជទ្រព្យឲ្យទៅជាទាន ដល់សមណព្រាហ្មណាចារ្យ និងស្មូមយាចកអ្នកកំសត់ទុគ៌តជាច្រើន ព្រះអង្គទ្រង់គង់នៅដរាបដល់សោយព្រះទិវាល័យក្ស័យព្រះជន្មទៅ បានទៅយកព្រះជាតិកំណើតកើតក្នុងស្ថានសួគ៌ ។

ឯសុរាក៏កើតឡើងជាលំដាប់ ១ ផ្សាយពាសពេញទាំងជម្ពូទ្វីប តាំងពីកាលនោះមក ។

សម្តេចព្រះបរមសាស្តាចារ្យ ទ្រង់នាំមកនូវព្រះធម៌ទេសនានេះ ហើយ ទ្រង់ប្រជុំជាតកថាៈ ព្រះបាទសព្វមិត្តនោះ លុះបរិវត្តនមក បានជាអានន្ទៈ, ឯសក្កទេវរាជ គឺជាតួអន្តតថាគតនេះឯង ។

កុម្ភជាតកំ និដ្ឋិតំ ។

ចប់កុម្ភជាតកតែប៉ុណ្ណេះ ។

## បញ្ជីសៀវភៅ

### ដែលពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយ

### ភាសាខ្មែរនឹងបាលី

| | | | |
|---|---|---|---|
| អំពីប្រាសាទខ្លះនៅអង្គរ ( ចគរ ) . . . . | ១ សៀវភៅថ្លៃ | | ១៣'០០ |
| សុរូបយាត្រឡើងស័ក . . . . . . . | | – | ៣'០០ |
| បព្វគណនាវិធី នឹងបព្វសម្រេច . . . . . | | – | ៣'០០ |
| វិធីបង្ការរោគ . . . . . . . | | – | ៦'០០ |
| ជយវរ្ម័នទី ៧ . . . . . . . | | – | ៥'០០ |
| បទានុក្រមភាមក្តើ . . . . . . . | | – | ២'០០ |
| មគ្គុទ្ទេសនគរ ភាគទី ១ . . . . . . | | – | ០'០០ |
| " ភាគទី ២ . . . . . . | | – | ០'០០ |
| ទស្សនាវដ្តីឆ្នាំ ១៩៤៩ មួយឆ្នាំ . . . . . | ១២ | – | ៩៦'០០ |
| " ១៩៥០ " . . . . . | " | – | ១៤៥'០០ |
| " ១៩៥១ " . . . . . | " | – | ១៤៥'០០ |
| " ១៩៥២ " . . . . . | " | – | ១៧៣'០០ |
| " ១៩៥៣ " . . . . . | " | – | ១៩២'០០ |
| " ១៩៥៤ " . . . . . | " | – | ២០០'០០ |
| " ១៩៥៥ " . . . . . | " | – | ២១០'០០ |
| " ១៩៥៦ " . . . . . | " | – | ២៣០'០០ |
| " ១៩៥៧ " . . . . . | " | – | ២៣០'០០ |
| ឯកសហស្សរាត្រីភាគទី១ . . . . . | ១ | – | ៥'០០ |
| " " ២ . . . . . . | | – | ៤'០០ |
| " " ៣ . . . . . . | | – | ៤'០០ |
| " " ៤ . . . . . . | | – | ៤'០០ |
| " " ៥ . . . . . . | | – | ៤'៥០ |
| " " ៦ . . . . . . | | – | ៣'០០ |

| | | | |
|---|---|---|---|
| ឯកសិមហស្រាវត្រីភាគ | ទី ៧ . . . . . . . . | ១សៀវភៅថ្លៃ | ៥,០០ |
| " | " ៨ . . . . . . . | – | ៥,០០ |
| " | " ៩ . . . . . . . | – | ៤,០០ |
| " | " ១០ . . . . . . . | – | ២,០០ |
| " | " ១១ . . . . . . . | – | ២,០០ |
| " | " ១២ . . . . . . . | – | ២,០០ |
| " | " ១៣ . . . . . . . | – | ៥,០០ |
| " | " ១៤ . . . . . . . | – | ៧,០០ |
| " | " ១៥ . . . . . . . | – | ១០,០០ |
| " | " ១៦ . . . . . . . | – | ៦,៥០ |
| " | " ១៧ . . . . . . . | – | ៥,៥០ |
| " | " ១៨ . . . . . . . | – | ៥,០០ |
| " | " ១៩ . . . . . . . | – | ៧,៥០ |
| " | " ២០ . . . . . . . | – | ៨,០០ |
| " | " ២១ . . . . . . . | – | ៨,០០ |
| " | " ២២ . . . . . . . | – | ៨,០០ |
| " | " ២៣ . . . . . . . | – | ៨,០០ |
| " | " ២៤ . . . . . . . | – | ៨,០០ |
| " | " ២៥ . . . . . . . | – | ៦,០០ |
| " | " ២៦ . . . . . . . | – | ៧,០០ |
| " | " ២៧ . . . . . . . | – | ៧,០០ |
| " | " ២៨ . . . . . . . | – | ៨,០០ |
| " | " ២៩ . . . . . . . | – | ៧,០០ |
| " | " ៣០ . . . . . . . | – | ៧,០០ |
| " | " ៣១ . . . . . . . | – | ៨,០០ |

| | | |
|---|---|---|
| ឯកសហស្រាក្រ៏ភាគទី ៣២ | . . . . . . | ១ សៀវភៅថ្លៃ ៨,០០ |
| " " ៣៣ | . . . . . . | – ៨,០០ |
| " " ៣៤ | . . . . . . | – ៨,០០ |
| " " ៣៥ | . . . . . . | – ៨,០០ |
| " " ៣៦ | . . . . . . | – ៨,០០ |
| " " ៣៧ | . . . . . . | – ៨,០០ |
| " " ៣៨ | . . . . . . | – ៨,០០ |
| វិសុទ្ធិមគ្គ ភាគទី ១ | . . . . . . | – ៥១.០០ |
| " " ២ | . . . . . . | – ៥០'០០ |
| " " ៣ | . . . . . . | – ៥០'០០ |
| វេយ្យាករណ៍សំស្ក្រឹត | . . . . . . . . | – ២៨.០០ |
| ព្រះបាទអសោក | . . . . . . . . | – ១៦,០០ |
| គម្ពីអាស៊ីទ្វីប | . . . . . . . . . | – ២៤,០០ |
| មហាវេស្សន្តរជាតក | . . . . . . . . | – ៤៣.០០ |
| សុភូតិសូត្រ | . . . . . . . . | – ១,៥០ |
| ភាណភិរៈ ឆាលី | . . . . . . . . | – ៣៨,០០ |
| ជនមោក្ខសង្ខេប | . . . . . . . . | – ៨'០០ |
| ធម៌ជនិមោក្ខ | . . . . . . . | – ២១'០០ |
| មរណានុស្សតិកម្មដ្ឋាន | . . . . . . . | – ៣,៥០ |
| អគ្គានុសាសនី | . . . . . . . | – ៦,៥០ |
| ផាផាជាតក | . . . . . . . . | – ១២.០០ |
| សតិបដ្ឋានសូត្រ និងសំវេគធម៌ | . . . . . | – ៨,៥០ |
| សម្ពន្ធមាលា | . . . . . . . . | – ៤១'០០ |
| វចនានុក្រមខ្មែរ ភាគ ១ | . . . . . . | – ១០៥.០០ |
| " ភាគ ២ | . . . . . . | – ១៣៦'០០ |

| | |
|---|---|
| អនត្តលក្ខណសូត្រ . . . . . . . ១ សៀវភៅថ្លៃ | ២,០០ |
| វិជ្ជាបរណកជាតិនិងគិរីមានន្ទសូត្រ . . . . . . – | ៦,០០ |
| បព្វជាខន្ធកសង្ខេប . . . . . . . . . – | ៨,៥០ |
| សុភាសិតប្បកាសិនី . . . . . . . . . – | ៣,០០ |
| កាលាមសូត្រនិងបរាភវសូត្រ . . . . . . – | ២,០០ |
| ជាយាសិភគិញ្ញសូត . . . . . . . . . – | ២,៥០ |
| គំរូក្បាច់ហ៊ាក់ខ្មែរ . . . . . . . . . – | ១២,០០ |
| អក្សរខ្មែរផាប់និងរូបសត្វ . . . . . . . . – | ០,០០ |
| សាមណេរវិន័យ . . . . . . . . . – | ៣,០០ |
| ពិធីទានសមាស ភាគ១ . . . . . . . – | ១៥,០០ |
| – ភាគ២ . . . . . . . . – | ១៣,៥០ |
| អនុមោទនាវិធី . . . . . . . . . . – | ៣,០០ |
| មាតាបិតុឧបដ្ឋានកថា . . . . . . . – | ៥,៥០ |
| សត្តបរិត្ត ទ្វាទសបរិត្ត . . . . . . . . – | ១៣,០០ |
| ធិហិបដិបត្តិពិស្តារ . . . . . . . . . – | ១០,០០ |
| សីលនិទ្ទេស . . . . . . . . . – | ១៦,០៤ |
| ធម្មប្រទីប . . . . . . . . . – | ១០,០០ |
| អវសោធកិច្ច . . . . . . . . . – | ១០,៥០ |
| មិលិន្ទបញ្ហា ភាគទី១ . . . . . . . . – | ២០,០០ |
| – ភាគទី២ . . . . . . . – | ១៨,០០ |
| ដើមកំណើតអង្គរ . . . . . . . . – | ៤,៥០ |
| អាឡវកសូត្រ . . . . . . . . – | ៥,០០ |
| អរិយសច្ចកថា . . . . . . . . – | ១០,០០ |
| វិជ្ជាប្រាំបីប្រការ . . . . . . . . . . . . . – | ១៤,៥០ |
| អភិធម្មត្ថសង្គហប្រែ . . . . . . . . . . . . – | ២៩,០០ |

| | | |
|---|---|---|
| ប្រស្នាវិន័យបិដកសង្ខេប | ១ សៀវភៅថ្លៃ | ៣២'៥០ |
| រតនប្បកា | – | ៧,០០ |
| ពុទ្ធមាមកវិធី | – | ៨,៥០ |
| បញ្ហាអភិធម្មប្បច្ចវេក្ខណៈ | – | ២,៥០ |
| ទានកថា | – | ៧,៥០ |
| វសលសូត្រ | – | ៣,០០ |
| ទសបារមីកថា | – | ៦,០០ |
| សៀវភៅយានជំនិះខ្មែរ | – | ០,០០ |
| គម្ពីរវេជ្ជសារ | – | ១០,៥០ |
| ពិហិបដិបត្តិសង្ខេប | – | ០,០០ |
| សុភទោសកថា | – | ១,៥០ |
| បញ្ញាសជាតក ប្រូ | – | ២៣,០០ |
| " " ជាលី | – | ១៦,០០ |
| គតិលោក ភាគទី ១ | – | ៤,០០ |
| " ២ | – | ៤,០០ |
| " " ៣ | – | ៤,០០ |
| " " ៤ | – | ៤,០០ |
| " " ៥ | – | ៤,០០ |
| " " ៦ | – | ៤,០០ |
| " " ៧ | – | ៤,០០ |
| " " ៨ | – | ៤,០០ |
| " " ៩ | – | ៤,០០ |
| " " ១០ | – | ៤,០០ |
| ព្រហ្មចរិយកថា | – | ១៥,០០ |
| គោលសមថកម្មដ្ឋាន | – | ៤,០០ |

| | | |
|---|---|---|
| សីមាវិនិច្ឆ័យ . . . . . . . | ១ សៀវភៅថ្លៃ | ២,០០ |
| មនោបុព្វកថា . . . . . . . | – | ៣,០០ |
| បែបអក្សរខ្មែរ . . . . . . . | – | ០,០០ |
| ប្រវត្តិព្រះមហាពោធិព្រឹក . . . . . | – | ២,០០ |
| មិត្រល្អ . . . . . . . | – | ០,០០ |
| ទសធម្មសូត្រ . . . . . . . | – | ០,០០ |
| ទំនៀមការផ្លាស់ខ្លួន . . . . . . | – | ៧,០០ |
| ទឹកទន្លេសាប . . . . . . | – | ០,០០ |
| ព្រះបង្ហួមកែវ . . . . . . . | – | ១,០០ |
| ព្រះរាជពិធីរាជាភិសេក . . . . . . | – | ៥,០០ |
| អក្ខរោសកថា . . . . . . . | – | ១,៥០ |
| អំពីព្រះពុទ្ធសាសនា . . . . . . | – | ៥១,០០ |
| ញាណកកថា . . . . . . . | – | ២,០០ |
| និំណកាលពុទ្ធចេតិយ . . . . . . | – | ០,០០ |
| នាគោបមាទំកថា . . . . . . | – | ១,៥០ |
| ១០០ គាថា . . . . . . . | – | ០,០០ |
| សារទេសនា . . . . . . . | – | ២,០០ |
| អនុត្តរិយសូត្រ . . . . . . . | – | ០,០០ |
| ពុទ្ធោវាទានុសាសនី . . . . . . | – | ៤,០០ |
| មហាបុរិសលក្ខណ | – | ១,០០ |
| បុណ្ណោវាទសូត្រ . . . . . . | – | ០,០០ |
| សំណាញ់កនធវត្ត . . . . . . | – | ១០,០០ |
| បិសាចស្នេហ . . . . . . | – | ០,០០ |
| កុម្ភជាតក . . . . . . . | – | ៣,០០ |
| ទេមាទេមសារណកថា . . . . . . | – | ០,០០ |
| ក្បួនរាជសីហ . . . . . . . | – | ០,០០ |

| | |
|---|---|
| សំដែងអំពីព្រះនិព្វាន . . . . . . . . . ១ សៀវភៅថ្លៃ | ០.០០ |
| យភាភិសធម៌ . . . . . . . . . . . . — | ០.០០ |
| អក្សរខ្មែរជាប់នឹងរូបភាពក្មេង . . . . . . . . — | ០.០០ |
| វុត្តោទយ . . . . . . . . . . . . — | ០.០០ |
| បការណវិសេសោ . . . . . . . . . . . . — | ០.០០ |
| សង្គាហោភិទសូត្រ . . . . . . . . . . . . — | ៦.០០ |
| ភាពក្មេងពីខ្សែ ១ ដល់ខ្សែ ១០ ពាក្យកាព្យ . . . . . . — | ៤.០០ |
| ពី ៧៥ ដល់ ៨០ . . . . . . . . . . . . — | ២.០០ |
| រឿងកាក . . . . . . . . . . . . — | ៧.០០ |
| គិរីមានន្ទសូត្រ . . . . . . . . . . . . — | ៣.០០ |
| អភិនវភាសិត . . . . . . . . . — | ៣.០០ |
| ពាក្យកាព្យថ្លែងរឿងពុទ្ធប្បវត្តិ . . . . . . . . — | ៣.០០ |
| ច្បាប់ល្បើកខ្ញូឆាតក្ដនហោបិន . . . . . . — | ០,០០ |
| ច្បាប់រំលឹកគាស់គឿន . . . . . . . — | ០,០០ |
| ច្បាប់ល្បើកថ្មី . . . . . . . . . — | ០,០០ |
| ភគនេតិ . . . . . . . . . — | ០,០០ |
| ច្បាប់ត្រីនេតិ . . . . . . . . . — | ០.០០ |
| ច្បាប់ក្រម . . . . . . . . . — | ០.០០ |
| បែបសកភិទ ឆ្នាំ ១៩៣១ . . . . . . . — | ០,៤៥ |
| — — ១៩៣២ . . . . . . . — | ០,៤៥ |
| — — ១៩៣៣ . . . . . . . — | ០,៤៥ |
| ច្បាប់កូនចៅ . . . . . . . . — | ០,០០ |
| ច្បាប់ល្បែងៗ ភាគ ១ . . . . . . . — | ៤,០០ |
| — ភាគ ២ . . . . . . . — | ០,០០ |
| ច្បាប់សុភាសិត . . . . . . . . . — | ៣.៥០ |

| | | |
|---|---|---|
| សប្បុរិសធម៌ . . . . . . . . . . . . . . . . . | ១ សៀវភៅថ្លៃ | ១,៥០ |
| ច្បាប់ព្រះរាជនិពន្ធប្រុសស្រីក្រមអ្វី . . . . . . . . . . . . . | | ២,០០ |
| សុភាសិតច្បាប់ស្រី . . . . . . . . . . . . . . . | – | ៥,០០ |
| ចំរៀងជាតិនិយម ភាគទី ១ . . . . . . . . . . . . . . | – | ៧,០០ |
| សេកសោមបណ្ឌិត . . . . . . . . . . . . . . . . | – | ៣,០០ |
| ច្បាប់កេរ្តិ៍កាល (ចាស់) . . . . . . . . . . . . . . | – | ០,៦០ |
| ព្រះត្រៃលក្ខណ៍និងសំវេគកថា . . . . . . . . . . . . . | – | ៤,០០ |
| ក្រុងសុភមិត្រ ភាគ ១ . . . . . . . . . . . . . . . | – | ៩,០០ |
| " " ២ . . . . . . . . . . . . . . . . | – | ៦,០០ |
| " " ៣ . . . . . . . . . . . . . . . | – | ៣,០០ |
| សំវេគនីយធម៌ . . . . . . . . . . . . . . . . | – | ២,០០ |

# សៀវភៅភាសាបារាំង

ពុទ្ធប្បវត្តិតាមផំរូបចិន(La vie du Bouddha en 49 Images)១សៀវភៅថ្លៃ១០,០០

| | | |
|---|---|---|
| ចំរៀងសន្តិភាព ( Chant de paix ) . . . . . . . | - | ១៥,០០ |
| ដើមកំណើតអង្គរ (l'Origine d'Angkor) . . . . . | - | ២០,០០ |
| ជ័យវរ្ម័នទី៧ ( Jayavarman VII ) . . . . . . . . | - | ១០,០០ |
| ពិធីទ្វាទសមាស ( Cérémonie des 12 mois) . . . . | - | ៣០,០០ |
| របាំខ្មែរ ( Danses Cambodgiennes ) . . . . . | - | ៧០,០០ |

## រូបភាពផ្សេង ៗ

| | | | |
|---|---|---|---|
| បេសនិយបត្ត . . . . . . . . . . . . . . . . | ១ | សន្លឹក | ០១,០០ |
| គេមិយជាតក . . . . . . . . . . . . . . . . | ១០ | - | ៥,០០ |
| សុវណ្ណសាមជាតក . . . . . . . . . . . . . . | - | - | ៥,០០ |
| មហាជនកជាតក . . . . . . . . . . . . . . | - | - | ៥,០០ |

ភ្នំពេញ រោងពុម្ពកុមារពាណិជ